ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# គំរោងជំនួយ ផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌ នៅកម្ពុជា ដំណាក់កាលទី៣

## របាយការណ៍សង្ខេបស្តីពីប្រតិបត្តិការ សកម្មភាពប្រចាំឆ្នាំ ២០០៨

ខែ មិនា ឆ្នាំ ២០០៩

Australian Government
AusAID
ផ្តល់មូលនិធិដោយទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិ

## សេចក្តីផ្តើម

នេះគឺជារបាយការណ៍ទី២ស្តីអំពីប្រតិបត្តិការសកម្មភាពប្រចាំឆ្នាំរបស់គម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា ដំណាក់កាលទី ៣ ។ របាយការណ៍នេះនឹងរៀបរាប់អំពីដំណើរការប្រព្រឹត្តទៅនៃគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា អំពីសកម្មភាពដែលបានគ្រោងទុក និងដំណើរវិវឌ្ឍន៍ទៅមុខដើម្បីសម្រេចអោយបាននូវគោលដៅនៃផ្នែកនីមួយៗ ។ ម៉្យាងទៀតរបាយការណ៍នេះនឹងសង្ខេបជូនអំពីការអនុវត្តគម្រោងចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៨ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ហើយនឹងរៀបរាប់អំពីការវិវឌ្ឍន៍ឈាមទៅសម្រេចអោយបាននូវសមិទ្ធិផលដែលបានគ្រោងទុក ចាប់តាំងពីពេលចាប់ផ្តើមអនុវត្តគម្រោងនៅខែមិថុនា ឆ្នាំ២០០៧ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ។

លទ្ធផលទាំងឡាយដែលមានរៀបរាប់នៅក្នុងរបាយការណ៍នេះ សុទ្ធតែជាទិន្នន័យដែលប្រមូលបានមកពីប្រភពមួយចំនួនដូចខាងក្រោម ៖

- ការស្ទង់មតិប្រចាំឆ្នាំ២០០៨ ពីសំណាក់ស្ថាប័នពាក់ព័ន្ធជាមួយនឹងគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា ដំណាក់កាលទី ៣ ដែលបានរៀបចំធ្វើឡើងដោយបុគ្គលិកមកពីដំរី (Domrei) ជាទីភ្នាក់ងារស្រាវជ្រាវ និងវាយតម្លៃក្នុងស្រុកដែលបានជួបសម្ភាសន៍ជាមួយស្ថាប័នពាក់ព័ន្ធនានាចំនួន ៧៣ ។
- សូចនាករដែលបានមកពីគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជាដំណាក់កាលទី ៣ ដោយផ្ទាល់គឺពឹងផ្អែកទៅលើទិន្នន័យរបស់ស្ថាប័នតុលាការ ។
- ទីប្រឹក្សា និងបុគ្គលិកជាតិរបស់គម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជាដំណាក់កាលទី ៣ ។
- ឯកសារ និងកំណត់ហេតុរបស់គម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជាដំណាក់កាលទី ៣ រួមទាំងរបាយការណ៍របស់ក្រុមទីប្រឹក្សាពិគ្រោះយោបល់ផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌ ។
- ប្រភពមកពីទីភ្នាក់ងារជាដៃគូ (រួមបញ្ចូលទាំងអត្ថបទដកស្រង់ចេញពីសារព័ត៌មាននានា) ។

## របកគំហើញសំខាន់ៗ

របកគំហើញដែលសំខាន់ជាងគេនោះគឺថា គ្រប់ផ្នែកទាំងអស់នៃគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជានេះកំពុងតែមានដំណើរការរីកចម្រើនទៅមុខយ៉ាងល្អប្រសើរក្នុងការជួយគាំទ្រដល់ការកែលម្អប្រព័ន្ធច្បាប់ និងយុត្តិធម៌ក៏ដូចជាការពង្រីក និងពង្រឹងចំណេះដឹង និងសមត្ថភាពក្នុងការអនុវត្តកាងាររបស់ទីភ្នាក់ងារពាក់ព័ន្ធសំខាន់ៗ និងដៃគូដទៃទៀត ។ ក្រុមស្រាវជ្រាវឯករាជ្យមួយដែលបានធ្វើការស្ទង់មតិប្រចាំឆ្នាំ២០០៨ ពីស្ថាប័នពាក់ព័ន្ធជាមួយនឹងគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា បានប្រមូលពត៌មានពីការផ្លាស់ប្តូរប្រព័ន្ធចំនួន ២៣២ ដែលទទួលបានការជួយសម្រួលការងារពីគម្រោងដោយបានគូសបញ្ជាក់ពីការផ្លាស់ប្តូរប្រព័ន្ធ និងឥរិយាបថ ហើយដែលបានបង្កើនប្រសិទ្ធភាព និងឱកាសសម្រាប់បង្កើននិរន្តរភាព ដែលជាគុណប្រយោជន៍ដល់គម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជាដំណាក់កាលទី ៣ ។

គម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា ផ្តោតទៅលើប្រព័ន្ធផ្លាស់ប្តូរមួយប្រកបដោយ និរន្តរភាព ដោយផ្អែកទៅតាមសេចក្តីប្រកាសទីក្រុងប៉ារីស និងត្រូវបកស្រាយបំភ្លឺ ដូចខាងក្រោម ៖

- ការបន្តចូលរួមវិភាគទានដល់ការអភិវឌ្ឍលើប្រព័ន្ធយុត្តិធម៌សំខាន់ៗទាំងបីផ្នែក ដែលកំពុងមានដំណើរការវិវឌ្ឍន៍ ទៅមុខយ៉ាងល្អប្រសើរដោយមានការគាំទ្រពីគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា (ច្បាប់នគរបាល ច្បាប់អប់រំកែប្រែ និងច្បាប់យុត្តិធម៌អនិតិជន) ។
- ការពង្រឹងភាពជាម្ចាស់ការក្នុងការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តន៍សកម្មភាពកំណែទម្រង់ ដែលបានបង្ហាញអោយឃើញតាមរយៈសមិទ្ធិផលការងារដ៏ល្អប្រសើរមួយ និងជំហរដ៏ច្បាស់លាស់របស់ក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោង នឹងបង្ហាញឡើងនូវសមិទ្ធិផលការងាររបស់ក្រុមពិនិត្យវាយតំលៃសំណើសុំមូលនិធិបត់បែន រួមទាំងលទ្ធផលដែលសម្រេចបាន និងការចូលរួមវិភាគទានពីស្ថាប័នពាក់ព័ន្ធសំខាន់ៗ និងសមភាគីនានា។
- លទ្ធផលរួមរបស់ផ្នែកផ្សេងៗទាំងអស់នៃគម្រោងក្នុងការពង្រឹងសមត្ថភាពរបស់ទីភ្នាក់ងារជាដៃគូ តាមរយៈសេចក្តីព្រាងស្តីពីមគ្គុទេសន៍នៃការធ្វើផែនការតាមវិស័យ និងតាមរយៈ សកម្មភាព ផ្សេងៗទៀត ដែលគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពថ្នាក់ដឹកនាំ ក្នុងការប្តេជ្ញាចិត្តលើនយោបាយកំណែទម្រង់ ការធ្វើផែនការ ការត្រួតពិនិត្យ និងការវាយតម្លៃ ។
- ការពង្រឹងជំនាញបច្ចេកទេសដែលគាំទ្រដល់គម្រោងជាអាទិភាព និងគោលដៅអន្តរវិស័យដែលអាចបង្កលក្ខណៈ ល្អបំផុតដល់លទ្ធផលដែលនឹងទទួលបានព្រមទាំងធ្វើអោយមាននិរន្តរភាព ។
- អនុវត្តន៍ការងារទាំងឡាយតាមរយៈ ការតំរឹមនិងការពង្រឹងជាមួយប្រព័ន្ធដល់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាការ គាំទ្រដល់យុទ្ធសាស្រ្តកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ រួមទាំងគាំទ្រការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលអាចធ្វើអោយគម្រោង អាចពង្រីការចូលរួមអោយមានប្រសិទ្ធភាពដល់ថ្នាក់ខេត្ត ដើម្បីគាំទ្រដោយផ្ទាល់ដល់ក្រុមជនដែលងាយរងគ្រោះ ។
- ការដឹកនាំ និងតួនាទីក្នុងការសម្របសម្រួលក្នុងភាពជាដៃគូ ជាមួយនឹងទីភ្នាក់ងារអូស្រ្តាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិ (AusAid) ដើម្បីគាំទ្រដល់សហគមន៍ដែលពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលសំខាន់ៗក្នុងសកម្មភាព តាមថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

## ផ្នែកទី ១

គម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា និងទីភ្នាក់ងារដាណឺម៉ាកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (ដានីដា) បានជួយគាំទ្រដល់អគ្គលេខាធិការដ្ឋានក្នុងការពង្រឹងតួនាទីរបស់ខ្លួន ក្នុងនាមជាលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាដើម្បីសម្រេចគោលដៅកែទម្រង់ទាំងឡាយ ។ ដោយអនុវត្តការងារក្នុងភាពជាដៃគូ ពួកគេបានធ្វើការរួមគ្នាជាមួយនឹងអគ្គលេខាធិការដ្ឋានធ្វើការអភិវឌ្ឍ និងសម្របសម្រួលសកម្មភាពនានា ដើម្បីអនុវត្តយុទ្ធសាស្រ្តកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដូចដែលត្រូវ បានបង្កើតនៅក្នុង "គម្រោងសកម្មភាពដើម្បី អនុវត្តយុទ្ធសាស្រ្តកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌" របស់រាជរដ្ឋាភិបាលកម្ពុជា ។

ទិន្នន័យ និងពត៌មានដែលប្រមូលបានបានបង្ហាញអោយឃើញថា អគ្គលេខាធិការដ្ឋានមានការរីកចម្រើនជាលំដាប់ ដូចជាសមត្ថភាពក្នុងការអនុវត្តយុទ្ធសាស្រ្តកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ពង្រឹងជម្រុញគោលដៅ

កំណែទម្រង់ និង ការវិវឌ្ឍន៍ហើយរៀបចំគម្រោងដោយបង្កើតកម្មវិធីកែទម្រង់ រួមទាំងការអភិវឌ្ឍនិតិវិធី និង ប្រព្រឹត្តិកម្មសម្រាប់ការត្រួត ពិនិត្យ និងការធ្វើរបាយការណ៍លើការរីកចម្រើនក្នុងការផ្តួចផ្តើមគំនិតធ្វើកំណែទម្រង់ ។ បុគ្គលិករបស់អគ្គលេខាធិការដ្ឋាន អនុវត្តការងារដោយសហប្រតិបត្តិការជាមួយដៃគូផ្សេងៗក៏មានការរីកចម្រើន ហើយ ត្រូវរាយការណ៍អំពីការរីកចម្រើននេះ និងជាកត្តាមួយក្នុងការផ្តល់របាយការណ៍ ស្តីពីការអនុវត្តសកម្មភាពការងារក្នុង ឆ្នាំ២០០៨ ដោយធៀបទៅនឹងឆ្នាំមុន។

ការងារទាំងនេះត្រូវបានបញ្ជាក់ដោយការរីកចម្រើនក្នុងផ្នែកសហប្រតិបត្តិការ នៃប្រព័ន្ធត្រួតពិនិត្យសូចនាករ តាមផ្នែកនីមួយ ដើម្បីវាយតម្លៃការវិវឌ្ឍន៍ក្នុងការអនុវត្តនៃយុទ្ធសាស្រ្តកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ទល់ជាមួយ នឹងសូចនាករ ដែលបានបង្ហាញការវិវឌ្ឍន៍នៃកិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍសេចក្តីព្រាងមគ្គុទេសន៍ធ្វើផែនការ តាមវិស័យ និងការប្រើប្រាស់ក្នុងការអនុវត្តកំណែទម្រង់ និងជាឧបករណ៍មួយដែលមាននិរន្តរភាព សៀវភៅផែនការនេះ ត្រូវបានប្រើប្រាស់ក្នុងការបញ្ចូលកំណែទម្រង់ដែលជាអាទិភាពរបស់នគរបាលជាតិ និងអគ្គនាយកដ្ឋានពន្ធនាគារជា គម្រោងយុទ្ធសាស្រ្ត និងជាគម្រោងប្រចាំឆ្នាំ (រាប់បញ្ចូលនាយកដ្ឋានទាំង៦របស់រនគរបាលជាតិ ។ សៀវភៅនេះក៏ត្រូវ បានប្រើប្រាស់ជាមគ្គុទេសន៍សម្រាប់ក្រុមការងាររបស់គម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា ក្នុងការគាំទ្រ ដល់ការអភិវឌ្ឍគម្រោងតុលាការគំរូទាំង៤ ។ ដៃគូសំខាន់ៗ និងបុគ្គលិករបស់ទីភ្នាក់ងារបានចាប់ផ្តើមគូសបញ្ជាក់ថា សមត្ថភាពក្នុងការធ្វើគម្រោងការងារ និងគម្រោងថវិការរបស់ពួកគេមានការរីកចម្រើនគួរអោយកត់សម្គាល់ ។

សរុបទៅការពិនិត្យមើលឡើងវិញនេះ បានបង្ហាញអោយឃើញពីការរីកចម្រើននៅក្នុងគម្រោងរបស់អគ្គស្នង ការដ្ឋាន ក្នុងការដឹកនាំ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូផ្សេងៗ (ដោយរួមទាំងភាគីជាអ្នកផ្តល់ជំនួយផងនៅក្នុងការ អនុវត្តយុទ្ធសាស្រ្តកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។ ភ័ស្តុតាងបង្ហាញយ៉ាងច្បាស់ពីការរីកចម្រើននៅក្នុងគម្រោង យុទ្ធសាស្រ្តរបស់អគ្គនាយកដ្ឋាននគរបាលជាតិ និងអគ្គនាយកដ្ឋានពន្ធនាគារ ខេត្តបន្ទាយមានជ័យ ខេត្តកណ្តាល រាជធានី ភ្នំពេញ និងខេត្តកំពង់ចាម ដោយអនុលោមទៅតាមសៀវភៅផែនការ ។ លើសពីនេះទៀត ក៏មានការរីកចម្រើនយ៉ាង ច្បាស់ចំពោះការត្រួតពិនិត្យនៅតាមទីភ្នាក់ងារសំខាន់ៗ និងនៅតាមតុលាការនានារួមទាំងមានការីកចម្រើនផ្នែកឥរិយាបថ និងការអនុវត្តការងារប្រកបដោយតម្លាភាពដែលជាតុលាការគំរូ ។ ការទទួលខុសត្រូវក្នុងការអនុវត្តសកម្មភាពនៅក្នុង តុលាការគំរូ នឹងមានចែងនៅក្នុងផ្នែកទី ៤ នៃគម្រោងការងារ (ខែកក្កដា-ខែធ្នូ) ឆ្នាំ២០០៩ ។

## ផ្នែកទី ២

គម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា បានគាំទ្រអោយមានការរីកចម្រើនគួរអោយកត់សម្គាល់ ក្នុងការបង្កើតសំណើរ និងការបង្កើតសកម្មភាពនានា ដែលទាក់ទងទៅនឹងវិធានការទប់ស្កាត់បទល្មើស និងរក្សាសុវត្ថិភាព សហគមន៍ជាមួយនឹងដៃគូតាមបណ្តាខេត្តនានា ។ ការរីកចម្រើនជាក់ស្តែងនេះគឺមកពីមានការគាំទ្រពីគម្រោងជំនួយផ្នែក ព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា បង្កើតវគ្គបណ្តុះបណ្តាលជាផ្លូវការ និងមិនផ្លូវការស្តីអំពីវិធានការទប់ស្កាត់បទល្មើស និង រក្សាសុវត្ថិភាពសហគមន៍ នៅតាមថ្នាក់ខេត្ត ស្រុក និងឃុំ ។ ការជ្រើសរើសអ្នកជំនួយការក្នុងវគ្គបណ្តុះបណ្តាលនៅថ្នាក់ ស្រុកបានជួយសម្រួលដល់ការធ្វើគម្រោងផែនការ និងការត្រួតពិនិត្យសកម្មភាពការងារនៅក្នុងឃុំ និងការផ្តល់ធនធាន តាមរយៈមូលនិធិបត់បែន ដើម្បីឧបត្ថម្ភថវិកាដល់គ្រប់សកម្មភាពរបស់គម្រោងទប់ស្កាត់បទល្មើស និងរក្សាសុវត្ថិភាព

សហគមន៍ ដែលបានកំណត់ក្នុងគម្រោង និងអនុវត្តនៅក្នុងក្របខ័ណ្ឌការងាប្រព្រឹត្តកម្មនៃផែនការវិនិយោគក្នុងឃុំ ។ ចំណុចនេះទទួលបានលទ្ធផលជាវិជ្ជមាន ។

ការងារនៅក្នុងផ្នែកនេះបានជួយដល់ការអនុវត្តសកម្មភាពរបស់គម្រោងអនុវត្ត យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ជាមួយនឹងដៃគូពីបណ្តាខេត្តក្រោមអនុស្សារណៈនៃកិច្ចព្រមព្រៀង ផ្ទាល់រវាងអភិបាលខេត្តរវាង អភិបាលខេត្ត និងរដ្ឋាភិបាលអូស្ត្រាលី ។ វត្តមានរបស់មន្ត្រីកាន់គម្រោងប្រចាំខេត្ត ដោយសហការជាមួយខេត្តបានធ្វើអោយមានលទ្ធផលជាវិជ្ជមានដល់ភាពជាម្ចាស់ការ និងការចូលរួមក្នុងគម្រោងទប់ស្កាត់បទល្មើស និងរក្សាសុវត្ថិភាពសហគមន៍ និងយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។ ភ័ស្តុតាងបានបង្ហាញអោយឃើញថា មានការរីកចម្រើនខាងផ្នែកទំនាក់ទំនងរវាងសង្គមស៊ីវិល (និងអង្គការមិនមែនរដ្ឋាភិបាល) ជាមួយនិងទីភ្នាក់ងារដែលជាដៃគូ ជាពិសេសនៅតាមថ្នាក់មូលដ្ឋាន និងជាមួយអគ្គនាយកដ្ឋានពន្ធនាគារ និងក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោងនៅថ្នាក់ជាតិ (ការស្វែងរកមូលនិធិបត់បែន) ។ ភ័ស្តុតាងក៏បានបញ្ជាក់ផងដែរថានៅក្នុងផ្នែកនេះ គម្រោងកំពុងតែពង្រឹងសមត្ថភាពដឹកនាំតាមថ្នាក់ខេត្តដើម្បីជួយគាំទ្រដល់ប្រជាជនក្រីក្រ និងងាយរងគ្រោះដោយប្រើបណ្តាប្រព័ន្ធ និងរចនាសម្ព័ន្ធរបស់ពួកគេ ដើម្បីជួយសម្រួលដល់ការងារសំខាន់ៗនៅក្នុងគម្រោង និងសម្រេចគោលដៅប្រកបដោយនិរន្តរភាព ។

លទ្ធផលវិជ្ជមានមួយទៀតគឺផ្នែកទី២នៃគម្រោងនេះគឺ បណ្តាអភិបាលខេត្ត និងក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោងបានប្រើមូលនិធិបត់បែន ប្រកបដោយប្រសិទ្ធភាព ដើម្បីផ្តល់ធនធាន (និងពង្រឹងសមត្ថភាព) ភាគីដែលជាអភិបាលខេត្តដើម្បីផ្តល់ថវិការដល់សកម្មភាពជាអាទិភាពរបស់សហគមន៍ តឹរមកម្មភាពរបស់គម្រោងទប់ស្កាត់បទល្មើស និងរក្សាសុវត្ថិភាពសហគមន៍ ជាមួយនឹងប្រព័ន្ធរបស់រាជរដ្ឋាភិបាល និងបានជួយសម្រួលទំនាក់ទំនងជាមួយសហគមន៍ និងប្រជាពលរដ្ឋដែលទទួលរងគ្រោះនៅតាមមូលដ្ឋាន ។

## ផ្នែកទី ៣

នៅឆ្នាំ២០០៨ តាមរយៈនៃការអនុវត្តនូវគោលការណ៍មគ្គុទេសន៍ធ្វើផែនការតាមវិស័យ គម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា បានជួយនគរបាលជាតិកម្ពុជា ក្នុងការបង្កើតគម្រោងយុទ្ធសាស្ត្រជាលើកដំបូង និងគម្រោងប្រចាំឆ្នាំរបស់នាយកដ្ឋាន ដែលបានស្តែងចេញនូវការកែទម្រង់ជាអាទិភាព ។ គម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា បានជួយ (និងបន្តជួយរហូតឆ្នាំ២០០៩) នគរបាលជាតិកម្ពុជា ប៉ូលីសសហព័ន្ធអូស្ត្រាលី និងអគ្គមេធាវីអូស្ត្រាលី ដើម្បីអភិវឌ្ឍបង្កើតច្បាប់ថ្មីមួយសម្រាប់ នគរបាលជាតិ ។ បច្ចុប្បន្ននេះច្បាប់ថ្មីនេះនៅជាសេចក្តីព្រាងនៅឡើយ។ ប្រសិនបើសេចក្តីព្រាងច្បាប់ថ្មី នេះពុំមានបញ្ហាទេ យើងនឹងបញ្ចូលបន្ថែមនូវចំណុចមួយចំនួនដែលទាក់ទិនទៅនឹងការត្រួតពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធរបស់នគរបាលជាតិ ដោយរាប់បញ្ចូលទាំងធនធានមនុស្សនៅក្នុងក្របខ័ណ្ឌការងារតាមលំដាប់ថ្នាក់នៃសមត្ថភាព ហើយគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា នឹងជួយអោយនគរបាលជាតិកម្ពុជាទទួលនូវការអភិវឌ្ឍក្នុងឆ្នាំ២០០៩ ។ ការអភិវឌ្ឍលើផ្នែកលំដាប់ថ្នាក់នៃសមត្ថភាពនេះនឹងជួយអោយមានការរីកចម្រើនក្នុងការបញ្ជាក់ពីមុខងារ និងតួនាទីដែលត្រូវបំពេញ របស់នគរបាលជាតិ ។ នេះគឺជាអន្តរាគមន៍ពីរាជរដ្ឋាភិបាលកម្ពុជា ដែលបានគ្រងទុកក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ និងយុទ្ធសាស្ត្រ

កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលជាអាទិភាពសម្រាប់នគរបាលជាតិហើយនឹងមាន ល្បឿននៃការអភិវឌ្ឍ លឿនជាងមុន ។

យោងទៅលើភ័ស្តុតាងដែលបានបង្ហាញនៅក្នុងរបាយការណ៍ខែមេសា ឆ្នាំ២០០៨ គម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា មានការរីកចម្រើនយ៉ាងខ្លាំងក្នុងការពង្រឹងសមត្ថភាពជាយុទ្ធសាស្ត្ររបស់នគរបាលជាតិ និងជំនាញក្នុងផ្នែកគ្រប់គ្រងផែនការ ។ គុណភាពខាងផ្នែកវិធីរៀបចំផែនការត្រូវបានពង្រឹងគួរអោយកត់សម្គាល់នេះ បញ្ជាក់អោយឃើញពីសមត្ថភាពខាងប្រតិបត្តិការ ។ ការរៀបចំគ្រប់គ្រងនគរបាលជាតិបានធ្វើអោយមានការចាប់ផ្តើមកំណែទម្រង់ ហើយគម្រោងទាំងអស់ត្រូវបានរៀបចំចងក្រងឡើងដោយបុគ្គលិកនគរបាលជាតិ ដែលរៀបចំគ្រប់គ្រងខ្លួនឯងដោយផ្ទាល់ជាមួយនឹងជំនួយបច្ចេកទេសពីគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា ។ ការគ្រប់គ្រងនគរបាលជាតិស័ក្តិសមនឹងទទួលបាននូវកិត្តិយសក្នុងការពង្រឹងប្រព័ន្ធផែនការ និងវិធីសាស្ត្រ ។

សមត្ថភាពបច្ចេកទេសរបស់នគរបាលជាតិជាពិសេសដែលទាក់ទិនទៅនឹងមុខងារខាងផ្នែកធ្វើកោសល្យវិច័យត្រូវបានពង្រឹង និងពង្រីកនៅឆ្នាំ២០០៨ ។ ការពង្រឹងផ្នែកកោសល្យវិច័យក៏ត្រូវបានពង្រីករហូតទៅដល់ក្រសួងរដ្ឋាភិបាលដោយសហការជាមួយអាជ្ញាធរខេត្ត ហើយសកម្មភាពទាំងឡាយត្រូវបានរៀបចំឡើង និងបានអនុវត្តដើម្បីបង្កើនឱកាសអោយប្រជាពលរដ្ឋ ដែលងាយរងគ្រោះអាចទទួលបានសេវាពីប្រព័ន្ធយុត្តិធម៌ ដោយពង្រឹងការគាំទ្រពីសំណាក់អន្តរស្ថាប័នដល់ជនដែលរងគ្រោះ ក្នុងករណីរៀបចំគ្រប់គ្រង និងធ្វើកោសល្យវិច័យតាមក្បួនវេជ្ជសាស្ត្រ ឧបត្ថម្ភដល់ជនរងគ្រោះដោយអំពើលើផ្លូវភេទ ។

ថ្វីត្បិតតែនៅមានបញ្ហាប្រឈមជាច្រើនក្នុងការគាំទ្រដល់នគរបាលជាតិ ដើម្បីពង្រឹងយុទ្ធសាស្ត្ររបស់ខ្លួន សមត្ថភាពខាងប្រតិបត្តិការ និងបច្ចេកទេស ប៉ុន្តែសមិទ្ធិផលមួយចំនួននៃគោលដៅទាំងឡាយនៅក្នុងផ្នែកទី៣ ត្រូវបានសម្រេច និងមានការបោះជំហានទៅមុខជាលំដាប់ ។

## ផ្នែកទី ៤

ផ្នែកទី៤នេះគឺផ្តោតទៅលើខែធ្នូ ឆ្នាំ២០០៨ គឺការបង្កើតសៀវភៅចុះបញ្ជីនីតិជនសម្រាប់តុលាការ ពិធីសារ និងនីតិវិធីជាមួយតុលាការជាដៃគូ និងការបង្កើតប្រព័ន្ធគ្រប់គ្រងរឿងក្តីសម្រាប់សាលាឧទ្ធរណ៍ ។

ឧបត្ថម្ភដល់បណ្តុតុលាការគំរូជាដៃគូអោយទទួលបានលទ្ធផលល្អក្នុងការចងក្រងគម្រោងយុទ្ធសាស្ត្រគំរូ ។ ផ្នែកនេះនឹងរៀបរាប់អំពីការទទួលខុសត្រូវក្នុងការបន្តជំនួយឧបត្ថម្ភដល់ការអនុវត្តគម្រោងតុលាការគំរូ (ដូចមានរាយការណ៍ជូននៅក្នុងផ្នែកទី ១) ។ របាយការណ៍ប្រចាំឆ្នាំបានបង្ហាញពីលទ្ធផលនៃការរីកចម្រើនឆ្ពោះទៅកាន់គោលដៅដែលបានគ្រោងទុក ។ ប្រព័ន្ធគ្រប់គ្រងទិន្នន័យថ្មីរបស់តុលាការ ដោយរាប់ទាំងបញ្ជីរាយនាម ការគ្រប់គ្រងឯកសារអេឡិចត្រូនិចរបស់តុលាការខេត្តកណ្តាល និងបន្ទាយមានជ័យ ត្រូវបានរៀបចំឡើងដើម្បីគ្រប់គ្រងរឿងក្តីអោយបានប្រសើរជាងមុន និងដើម្បីអោយមានតម្លាភាពជាងមុនក្នុងការគាំទ្រដល់អនីតិជន មនុស្សពេញវ័យ និងជនដែលងាយរងគ្រោះ ដែលមានវត្តមាននៅមុខតុលាការកម្ពុជា ។

ការញែកអនីតិជននិងមនុស្សពេញវ័យចេញបញ្ជីចុះឈ្មោះរួម ផ្សំជាមួយនឹងច្បាប់ថ្មីសម្រាប់យុត្តិធម៌នីតិជន និងអាចទ្រួសត្រាយផ្លូវមួយឈានទៅរកការរីកចម្រើនក្នុងក្របខ័ណ្ឌការងារធ្វើផែនការរៀបចំ អនុវត្តការងារ

ត្រួតពិនិត្យ និង វាយតម្លៃតុលាការយុត្តិធម៌ អនីតិជននៅកម្ពុជា ។ តាមរយៈសកម្មភាពដែលបានអនុវត្ត និងការបង្ហាញអំពីបច្ចេកទេសរបស់ក្រុមការងារយុត្តិធម៌កុមារ ផ្នែកទី៤ នេះបានចូលរួមវិភាគទានដ៏មានសារៈសំខាន់ និងគួរជាទីពេញចិត្តដល់ច្បាប់សម្រាប់យុត្តិធម៌ អនីតិជនក៏ដូចជាការកែលម្អក្នុងផ្នែកគ្រប់គ្រងរឿងក្តី និងតម្លាភាពក្នុងបណ្តាតុលាការជាដៃគូ ។

ការងារដែលបានសម្រេចនៅក្នុងផ្នែកនេះគឺមានលក្ខណៈបច្ចេកទេសដោយផ្តោតទៅលើការពង្រឹងប្រព័ន្ធ និងការអនុវត្តអោយបានល្អជាងមុនក្នុងការរៀបចំគ្រប់គ្រងសំណុំរឿង ។ នាពេលអនាគតសកម្មភាពទាំងអស់ នឹងត្រូវផ្តោតទៅលើក្រសួងយុត្តិធម៌ និងនាយកដ្ឋានលើសមត្ថភាពរៀបចំ និងធ្វើផែនការ គ្រប់គ្រងថវិកា និងត្រួតពិនិត្យដើម្បីគាំទ្រដល់ការផ្តួចផ្តើមគំនិតក្នុងការធ្វើកំណែទម្រង់ ។

## ផ្នែកទី ៥

គម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា បានទទួលលទ្ធផលជាវិជ្ជមាននៅក្នុងផ្នែកនេះ ។ គម្រោងនេះបានពង្រឹងសមត្ថភាពអគ្គនាយកដ្ឋានពន្ធនាគារក្នុងការអនុវត្តកម្មវិធីកែទម្រង់ពន្ធនាគារ និងការគ្រប់គ្រងពន្ធនាគារ ជាអាទិភាពតាមរយៈលទ្ធផលសំខាន់ៗមួយចំនួន ។ គម្រោងក៏បានគាំទ្រដល់ការអភិវឌ្ឍមួយចំនួន ដូចជា សេចក្តីព្រាងច្បាប់ព្រហ្មទណ្ឌថ្មី គម្រោងយុទ្ធសាស្ត្ររបស់អគ្គនាយកដ្ឋានពន្ធនាគារ គម្រោងប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋានពន្ធនាគារលើកដំបូង (ដែលត្រូវបានទទួលស្គាល់ដោយក្រសួងមហាផ្ទៃ ក្នុងនាមជានាយកដ្ឋានដែលមានសិទ្ធិស្វ័យសម្រេច) និងសមត្ថភាពរបស់អគ្គនាយកដ្ឋានពន្ធនាគារ ក្នុងការរៀបចំធ្វើសន្និសីទបង្ហាញជូនពីផែនការប្រចាំឆ្នាំដល់បណ្តាតំណាងសង្គមស៊ីវិលនានា ។ នេះគឺជាលទ្ធផលវិជ្ជមានសម្រាប់ផ្នែកនេះ ។ ដូចយើងបានឃើញនៅក្នុងរបាយការណ៍ពីលទ្ធផលការងាររួចមកហើយថានេះគឺជាលើកដំបូងហើយដែលអគ្គនាយកដ្ឋានពន្ធនាគារបានរៀបចំសន្និសីទជាសាធារណៈ ដោយបង្ហាញជូនពីគោលដៅ និងផែនការអនាគតរបស់ខ្លួន ហើយក៏គឺជាលើកដំបូងដែរដែលបណ្តាអង្គការមិនមែនរដ្ឋាភិបាលត្រូវបានអញ្ជើញអោយចូលរួមក្នុងការធ្វើផែនការរបស់អគ្គនាយកដ្ឋានពន្ធនាគារ ។ ដើម្បីជំរុញអោយមានការចូលរួមកាន់តែច្រើននៅក្នុងធ្វើផែនការរបស់ខ្លួន និងសមត្ថភាពរបស់អគ្គនាយកដ្ឋានពន្ធនាគារក្នុងការពង្រឹងពិធីរាយការណ៍ដើម្បីកែទម្រង់នាយកដ្ឋាន និងធ្វើការជាមួយស្ថាប័នដែលពាក់ព័ន្ធរួមទាំង សង្គមស៊ីវិលក្នុងការកំណត់អាទិភាព និងបង្កើតអោយមានឱកាសកាន់តែច្រើនសម្រាប់និរន្តរភាពនៃការផ្តួចផ្តើមគំនិត ។

គម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា បានពង្រឹងសមត្ថភាពអគ្គនាយកដ្ឋានពន្ធនាការក្នុងការឆ្លើយតបប្រកបដោយស្មារតីសហប្រតិបត្តិការទៅនឹងក្រសួងសុខាភិបាលអំពីតម្រូវការផ្នែកសម្ភារៈ និងស្មារតីរបស់ពិរុទ្ធជនតាមរយៈការបន្តជំនួយឧបត្ថម្ភដល់អគ្គនាយកដ្ឋានពន្ធនាគារ ដើម្បីជួយអោយមានការកែទម្រង់ខាងផ្នែកប្រព័ន្ធដាក់ទោសទណ្ឌ និងការស្តារនីតិសម្បទាដើម្បីធ្វើយ៉ាងណាអោយបុគ្គលិក និងពិរុទ្ធជនសុទ្ធតែបានទទួលផលប្រយោជន៍ខាងផ្នែកសុខភាព និងសុខាមាលភាព ។ គម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា ក៏បានជួយអគ្គនាយកដ្ឋានពន្ធនាគារអោយពិនិត្យឡើងវិញនូវអនុក្រឹត្យលេខ ១១ និងលេខ ៨៣ ដែលមានស្រាប់ស្តីអំពីការផ្លាស់ប្តូរពិរុទ្ធជន និងសម្ភារៈក្នុងបន្ទប់ឃុំឃាំង ក៏បានគិតទៅដល់ការកើនឡើងនូវចំនួនពិរុទ្ធជន និងការឡើងតម្លៃទំនិញនៅតាមទីផ្សារ ។ ការពិនិត្យឡើង

វិញនេះក៏បានយកចិត្តទុកដាក់ទៅដល់តម្រូវការពិសេសរបស់ស្ត្រីដែលជាប់ឃុំឃាំង និងស្ត្រីដែលមានកូននៅជាប់ក្នុងមន្ទីរឃុំឃាំងជាមួយពួកគេ ។

គម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា បានជួយឧបត្ថម្ភដល់អគ្គនាយកដ្ឋានពន្ធនាគារក្នុងការចងក្រងបង្កើតច្បាប់ព្រហ្មទណ្ឌថ្មី ដែលមិនត្រឹមតែជួយអគ្គនាយកដ្ឋានពន្ធនាគារអោយកំណត់អំពីជម្រើសផ្សេងៗសម្រាប់សហគមន៍ពន្ធនាគារ ដែលជាចំណុចមួយនៃគោលដៅនៅក្នុងផ្នែកទី ៥ ប៉ុន្តែវាថែមទាំងនាំផ្លូវឆ្ពោះទៅកាន់ការអភិវឌ្ឍក្របខ័ណ្ឌការងារនយោបាយ និងច្បាប់នៅក្នុងសហគមន៍ពន្ធនាគារ ។ អគ្គនាយកដ្ឋានពន្ធនាគារមានចក្ខុវិស័យច្បាស់លាស់ក្នុងការកែទម្រង់ពន្ធនាគារ ហើយបានបំពេញការងារយ៉ាងស្វិតស្វាញដើម្បីទទួលបានលទ្ធផលនេះ ។

## ផ្នែកទី ៦

នៅក្នុងរយៈពេលនៃការធ្វើរបាយការនេះការគ្រប់គ្រងគម្រោងជំនួយផ្នែកព្រហ្មទណ្ឌនិងយុត្តិធម៌នៅកម្ពុជា បានវិវរចាកពីការអនុវត្តការងារតាមទម្លាប់ចាស់មកទទួលយកនូវរបៀបការងារមួយ ដែលប្រកបដោយលក្ខណៈទស្សនៈវិជ្ជា និង ស៊ីសង្វាក់គ្នាជាមួយនឹងសេចក្តីប្រកាសនៅទីក្រុងប៉ារីស និងផែនការសកម្មភាពទីក្រុងអាក្រា (AAA) ដើម្បីអោយមានប្រសិទ្ធភាពក្នុងការផ្តល់សេវាកម្ម និងសម្រេចគោលដៅកំណែទម្រង់ប្រកបដោយនិរន្តរភាព ។ នៅក្នុងពេលអនុវត្តគម្រោងនេះជំនួយបច្ចេកទេសពីបណ្តា ស្ថាប័នអន្តរជាតិ និងមានការថយចុះ ចំណែកឯតួនាទីនិងការទទួលខុសត្រូវថ្នាក់ជាតិវិញ នឹងមានការកើនឡើងជាលំដាប់ ។

មូលនិធិបត់បែន បានក្លាយមកជាកត្តាលីករដ៏សំខាន់មួយក្នុងការពង្រឹងភាពជាម្ចាស់ចំពោះសកម្មភាពកំណែទម្រង់នានាដោយក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោង ក្រុមត្រួតពិនិត្យរបស់មូលនិធិបត់បែនបានប្រកាន់យកការទទួលខុសត្រូវក្នុងការគ្រប់គ្រងរបស់ខ្លួន ហើយបានបង្ហាញអោយឃើញពីគុណភាពដែលកើនឡើងជាលំដាប់ក្នុងការកំណត់អាទិភាពដល់ការយល់ព្រម និងការវាយតម្លៃធនធានរបស់មូលនិធិបត់បែន ។ សមត្ថភាពរបស់ក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោងក្នុងការឧបត្ថម្ភថវិកាដល់សកម្មភាពនានារបស់អង្គការមិនមែនរដ្ឋាភិបាល និងកម្មវិធីជួយដល់ប្រជាពលរដ្ឋដែលងាយរងគ្រោះអាចទទួលសេវាពីប្រព័ន្ធយុត្តិធម៌បាន និងសម្រាប់សហគមន៍ទូទៅ បានទទួលលទ្ធផលជាវិជ្ជមាន។ ភ័ស្តុតាងនៃការឧបត្ថម្ភពីគម្រោងជំនួយផ្នែកព្រហ្មទណ្ឌនិងយុត្តិធម៌នៅកម្ពុជានេះ គឺទំនាក់ទំនងជាមួយនឹងក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោង ក្នុងការបង្កើនសមត្ថភាពអោយចូលរួមជាមយយបណ្តាអង្គការក្នុងសហគមន៍ ។

ការត្រួតពិនិត្យ និងការវាយតម្លៃក្របខ័ណ្ឌការងារនៅតែបន្តអភិវឌ្ឍហើយត្រូវបានវាយតម្លៃកម្រិតលទ្ធផលដែលទទួលបាននៅក្នុងរបាយការណ៍នេះជាលើកដំបូងតាំងពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៧ ដោយបានរៀបរាប់លម្អិតនៅក្នុងសេចក្តីផ្តើម ។ របាយការណ៍នេះនឹងនៅតែត្រូវពិនិត្យមើលឡើងវិញ ហើយធ្វើការកែតម្រូវក្នុងរយៈពេលផែនការប្រចាំឆ្នាំ ។

នីតិវិធីរបស់សៀវភៅនៅតែបន្ត និងកែសម្រួលដោយមានបញ្ចូលទាំងប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស ការជ្រើសរើសបុគ្គលិក ការវាយតម្លៃ ការធ្វើជម្រើស និងបញ្ចូលការអនុវត្តប្រព័ន្ធគ្រប់គ្រងថ្លៃឈប់សម្រាកប្រព័ន្ធគ្រប់គ្រងថវិកា និងការណែនាំរបស់មូលនិធិបត់បែន ។

ប្រធានក្រុមការងារថ្មីមួយរូប និងទីប្រឹក្សាប្រព័ន្ធយុត្តិធម៌ត្រូវបានតែងតាំង លិខិតបង្គាប់ការត្រូវបានពិនិត្យឡើងវិញ និងក្របខ័ណ្ឌគ្រប់គ្រងការបំពេញការងារត្រូវបានត្រួតពិនិត្យឡើងវិញ និងធ្វើអោយមានលក្ខណៈផ្លូវការជាងមុន ។ នៅខែមិថុនា ឆ្នាំ២០០៩ អនុប្រធានក្រុមការងារ (ទីប្រឹក្សានៃគម្រោងទប់ស្កាត់បទល្មើស និងរក្សាសុវត្ថិភាពសហគមន៍ បានលាចេញពីការងារ ។ តំណែងនេះពុំទាន់ត្រូវបានជំនួសនៅឡើយទេហើយអនុប្រធានក្រុមការងារថ្មី ដែលត្រូវបានតែងតាំងនោះគឺ Cheryl Clay ដែលឥឡូវត្រូវបានតែតាំងជាអនុប្រធានក្រុមការងារ និងទីប្រឹក្សារបស់សហគមន៍ពន្ធនាគារ ។ ការងារទំនាក់ទំនងរវាងគម្រោងជំនួយផ្នែកព្រហ្មទណ្ឌនិងយុត្តិធម៌នៅកម្ពុជា ជាមួយនឹងទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិ ត្រូវបានរឹតចំណងបន្តឹង និងកាន់តែស្អិតរមួតឡើង ។

## បញ្ហាអន្តរវិស័យ

គម្រោងជំនួយផ្នែកព្រហ្មទណ្ឌនិងយុត្តិធម៌នៅកម្ពុជា បានជួយធ្វើអោយមានការផ្លាស់ប្តូរជាវិជ្ជមានទាក់ទិនទៅនឹងអនីតិជន និងស្ត្រីនៅឆ្នាំ២០០៨ ។ គម្រោងនេះមានគោលដៅគាំទ្រដល់គម្រោងសកម្មភាពនៅក្នុងផ្នែកនីមួយៗ ។ ការវិភាគរាល់ពត៌មានត្រួតពិនិត្យទាំងអស់បង្ហាញអោយឃើញថា សកម្មភាពដែលបានគ្រោងទុកមួយចំនួនធំ សុទ្ធតែបានសម្រេចប្រកបដោយលទ្ធផលល្អ និងត្រូវបានកត់ត្រាចូលក្នុងរបាយការណ៍ ។

កម្មវិធីសាកល្បងអំពីអំពើហឹង្សាលើផ្លូវភេទនៅខេត្តកណ្តាល បានជួយគាំទ្រដល់ប្រជាពលរដ្ឋដែលងាយរងគ្រោះ និងជាជនដែលរងគ្រោះដោយអំពើហឹង្សាលើផ្លូវភេទ ។ ការផ្តួចផ្តើមគំនិតនេះបានបង្ហាញលទ្ធផលជាវិជ្ជមានក្នុងការសហការជាមួយអាជ្ញាធរខេត្ត : ការធ្វើសមាហរណកម្មទៅក្នុងផ្នែកណាដែលខ្លាំងជាងគេ ។ ការពង្រីកភាពជាដៃគូរវាងរាជរដ្ឋាភិបាលជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល និងការផ្តល់សេវាគាំទ្រដល់ជនរងគ្រោះដែលពុំបាលឆ្លងកាត់តាមប្រព័ន្ធតុលាការ ។ ការគាំទ្ររបស់ក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោង ចំពោះសកម្មភាពទាំងនេះសុទ្ធតែបានទទួលបានលទ្ធផលដ៏ល្អប្រសើរ ។

គម្រោងតុលាការគំរូបានផ្តោតទៅលើមធ្យោបាយផ្សេងៗ ដែលអាចជួយដល់ប្រជាពលរដ្ឋដែលងាយរងគ្រោះ អាចទទួលសេវាកម្មពីប្រព័ន្ធយុត្តិធម៌បាន (មានស្ត្រី និងកុមារ) ។ ការអនុវត្តបញ្ជីចុះឈ្មោះនៅតាមគ្រប់តុលាការគំរូនឹងទៅជាកត្តាលើករមួយជួយដល់ការតាមដាន នឹងគ្រប់គ្រងសំណុំរឿងបទឧក្រិដ្ឋ និងដីការរបស់តុលារចំពោះនិតិជន និងស្ត្រី ។ ការជួយគាំទ្រដល់ក្រុមការងារតុលាការសម្រាប់កុមារ និងច្បាប់ថ្មីសម្រាប់នីតិជន និងអាចផ្តល់មូលដ្ឋានគ្រឹះដើម្បីអនុវត្តការកែទម្រង់តុលាការអនីតិជននៅក្នុងផ្នែកនេះ ។

គម្រោងជំនួយផ្នែកព្រហ្មទណ្ឌនិងយុត្តិធម៌នៅកម្ពុជា បានទទួលលទ្ធផលជាវិជ្ជមានខាងផ្នែកយេនឌ័រ ដោយមានរាប់បញ្ចូលទាំងការកែលម្អផ្នែកឥរិយាបថរបស់នគរបាល និងសហគមន៍ និងការអនុវត្តការងារដើម្បីកាត់បន្ថយអំពើហឹង្សាក្នុងគ្រួសារ និងការរំលោភបំពានលើផ្លូវភេទ អប់រំលើកកម្ពស់ស្មារតីរបស់សហគមន៍អោយចេះស្វែងរកទីណា អាចមានជំនួយឧបត្ថម្ភដល់ជនរងគ្រោះដោយអំពើហឹង្សាក្នុងគ្រួសារ និងដោយការរំលោភបំពានលើផ្លូវភេទ ។ បង្កើតក្រុមការងារបញ្ជ្រាបយេនឌ័រ ។ ការរីកចម្រើនជាលំដាប់លើផ្នែកគម្រោងសកម្មភាពបញ្ជ្រាបយេនឌ័រ ដោយសហការជាមួយដៃគូនានា (នៅឆ្នាំ២០០៧ ក្រុមការងារដូចនេះមិនទាន់មាននៅឡើយទេ) ការអនុវត្តការកែទម្រង់ផ្នែកយេនឌ័រនៅតាមស្ថាប័ន និងតាមបណ្តាខេត្តជាដៃគូ ។ ការជួយគាំទ្របន្ថែមដល់ភាពស្មើគ្នារវាងបុរស និងស្ត្រីដែលជាតម្រូវការនៅក្នុង

ក្រសួងយុត្តិធម៌ ។ សេចក្តីព្រាងយុទ្ធសាស្ត្រមេរោគអេដស៍/ជំងឺអេដស៍ និងសេចក្តីព្រាងយុទ្ធសាស្ត្រច្បាប់សម្រាប់អនីតិជន ត្រូវបានស្រាវជ្រាវ និងសហការចងក្រងឡើងក្នុងរយៈពេលធ្វើរបាយការណ៍នេះ ។